**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ : ៤៥៧ សហវ.ប្រក.ចមហ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និង កម្រៃរដ្ឋបាលពាក់ព័ន្ធនានា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ

គ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញ ព្រះរាជក្រមលេខ នស/រកប/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ប.ក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យ លេខ ៦៤ អនក្រ បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពី ការអនុវត្តច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី រដ្ឋទេយ្យចំណូល
- អនុវត្តតាមសារចរណែនាំ លេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- អនុវត្តន៍តាមបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## <u>សម្រេច</u>

**ប្រការ ១** : អនុញ្ញាតឱ្យយកកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ដូចជាការបញ្ជាក់ អំពីការប្រើប្រាស់ ឬ មិនប្រើប្រាស់ម៉ាក ការផ្លាស់ប្តូរផ្សេងៗ ការលុបម៉ាកចេញពីបញ្ជី ការចុះបញ្ជីសាឡើងវិញ និងការបោះពុម្ពផ្សាយ ។

**ប្រការ ២** : ត្រូវបានកំណត់កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ពន្ធ័នានា ដូចខាងក្រោម :

| ល.រ | ពិពណ៌នា | ឯកត្តា | តម្លៃ (គិតជាប្រាក់រៀល) |
|---|---|---|---|
| | **I- ការចុះបញ្ជីម៉ាក** | | |
| ១- | ការដាក់ពាក្យសុំចុះបញ្ជីម៉ាក | មួយម៉ាក និងមួយជំពូក | ២០.០០០ រៀល |
| ២- | ការចុះបញ្ជីម៉ាក (សុពលភាព ១០ឆ្នាំ) | មួយម៉ាក និងមួយជំពូក | ១៨០.០០០ រៀល |
| | **II- ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក** | | |
| ៣- | ការដាក់ពាក្យ និង ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| | **III- ការផ្លាស់ប្តូរផ្សេងៗ** | | |
| ៤- | ការកត់ត្រា ការផ្ទេរកម្មសិទ្ធិម៉ាក (Assignment) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៥- | ការកត់ត្រា ការប្តូរឈ្មោះ ឬការរួមបញ្ចូលគ្នា នៃម្ចាស់ម៉ាក (Name Change and Merger) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៦- | ការកែតម្រូវនានា (ជាកំហុសរបស់អ្នកដាក់ពាក្យ) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៧- | ការកត់ត្រា ការប្តូរឈ្មោះអាសយដ្ឋាន (Address Change) (ក្នុងករណីប្តូរតែអាសយដ្ឋានមួយប៉ុណ្ណោះ) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| | **IV- ការលុបម៉ាក** | | |
| ៨- | ការលុបម៉ាកចេញពីបញ្ជី (បង់ដោយអ្នកស្នើសុំលុប) | មួយវិញ្ញាបនប័ត្រ | ២០០.០០០ រៀល |

| | | | |
|---|---|---|---|
| | **V- ការចុះបញ្ជីម៉ាកសាឡើងវិញ** | | |
| ៩- | ការដាក់ពាក្យ និងការចុះបញ្ជីម៉ាកសាឡើងវិញ | មួយម៉ាក និងមួយជំពូក | ២០០.០០០ រៀល |
| | **VI- ការបោះពុម្ពផ្សេងទៀត (ប្រសិនជាមាន)** | | |
| ១០- | ទំហំតូចជាង ១/៣ នៃក្រដាស A4 | មួយឯកត្តា | ៤០.០០០ រៀល |
| ១១- | ទំហំ ១/៣ នៃក្រដាស A4 | មួយឯកត្តា | ៨០.០០០ រៀល |
| ១២- | ទំហំ ១/២ នៃក្រដាស A4 | មួយឯកត្តា | ១២០.០០០ រៀល |
| ១៣- | ទំហំ ៣/៤ នៃក្រដាស A4 | មួយឯកត្តា | ២០០.០០០ រៀល |
| ១៤- | ទំហំ A4 | មួយឯកត្តា | ៤០០.០០០ រៀល |

**ប្រការ ៣ :** ក- ការគ្រប់គ្រងចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្តតាមនីតិវិធី នៃកិច្ចសហប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ ដោយត្រូវបង់ ១០០% ចូលថវិការដ្ឋ ។

ខ- ចំពោះចំណូល ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបង់ចំណូលនេះចូលរតនាគារជាតិ ដោយអនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

គ- ក្រសួងពាណិជ្ជកម្ម ត្រូវបូកសរុបធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៤ :** ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្ត តាមរយៈរដ្ឋទេយ្យករចំណូលនៅក្រសួងពាណិជ្ជកម្ម។

**ប្រការ ៥ :** ការផ្តល់ប្រាក់ឧបត្ថម្ភដល់ការងារគ្រប់គ្រង និង ប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៦ :** កម្រៃរដ្ឋបាលក្នុងការបោះពុម្ពផ្សាយម៉ាក ដែលបានចុះបញ្ជីរួចហើយ ក្នុងព្រឹត្តិប័ត្រផ្លូវការ នឹងត្រូវកំណត់នៅពេលក្រោយ ។

**ប្រការ ៧ :** បទប្បញ្ញត្តិ ឬ ប្រកាសទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- ដូចប្រការ ៨ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ